# នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង
# នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 27-Jan-2012, 15:13
CMS/CFO: Kauv Keoratanak

## ព័ត៌មានពិស្តារនៃការដាក់ឯកសារ

| | | |
|---|---|---|
| សំណុំរឿងលេខ | : | ០០២/១៩-០៩-២០០៧-អវតក/អជសដ |
| ដាក់ទៅ | : | អង្គជំនុំជម្រះសាលាដំបូង |
| ថ្ងៃដាក់ | : | ថ្ងៃទី២៧ ខែមករា ឆ្នាំ២០១២ |
| ភាគីអ្នកដាក់ | : | សហព្រះរាជអាជ្ញា |
| ភាសាដើម | : | អង់គ្លេស |

## ចំណាត់ថ្នាក់ឯកសារ

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារកំណត់ដោយអង្គជំនុំជម្រះសាលាដំបូង: សាធារណៈ/Public

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:

ការពិនិត្យចំណាត់ថ្នាក់ឯកសារបណ្ដោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

---

# សំណើរបស់សហព្រះរាជអាជ្ញា សុំបញ្ចូលទីតាំងឧក្រិដ្ឋកម្មបន្ថែម នៅក្នុងវិសាលភាពនៃការជំនុំជម្រះសំណុំរឿង ០០២/១

---

**អ្នកដាក់ឯកសារ:**

សហព្រះរាជអាជ្ញា:

លោកស្រី ជា លាង

លោក Andrew CAYLEY

**អ្នកទទួលឯកសារ:**

អង្គជំនុំជម្រះសាលាដំបូង:

ចៅក្រម និល ណុន, ប្រធាន

ចៅក្រម Silvia CARTWRIGHT

ចៅក្រម យ៉ា សុខន

ចៅក្រមJean-Marc LAVERGNE

ចៅក្រម យូ ឧត្តារា

សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី:

ពេជ អង្គ

Elisabeth SIMONNEAU FORT

**ចម្លងជូន:**

ជនជាប់ចោទ:

នួន ជា

អៀង សារី

ខៀវ សំផន

មេធាវីការពារក្តីជនជាប់ចោទ:

លោក សុន អរុណ

លោក Michiel PESTMAN

លោក Victor Koppe

លោក អាង ឧត្តម

លោក Michael G.KARNAVAS

លោក គង់ សំអុន

លោក Arthur VERCKEN

លោក Jacques VERGÈS

# I. សេចក្ដីផ្ដើម និងប្រវត្តិនីតិវិធី

១- នៅក្នុងសេចក្ដីសម្រេចបំបែកកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០២ របស់ខ្លួន ដែលបំបែកទៅជាការជំនុំជម្រះជាច្រើនខុសៗគ្នា អង្គជំនុំជម្រះសាលាដំបូង[1] ("អង្គជំនុំជម្រះ") បានបញ្ជាក់ថា៖

> ... *ក្នុងពេលណាមួយអាចសម្រេចបញ្ចូលនៅក្នុងសវនាការដំបូងនូវចំណែកនៃដីកាដំណោះស្រាយក្នុងសំណុំរឿង ០០២ ដោយគិតពីសិទ្ធិរបស់មេធាវីការពារក្ដីដែលនឹងត្រូវផ្ដល់នូវឱកាសដើម្បីត្រៀមរៀបចំកិច្ចការពារឱ្យមានប្រសិទ្ធភាព ហើយភាគីទាំងអស់នឹងត្រូវជូនដំណឹងទាន់ពេលវេលា*[2]។

២- ដោយបានពិចារណា និងបដិសេធសំណើរបស់សហព្រះរាជអាជ្ញាសុំឱ្យពិចារណាឡើងវិញ ចំពោះការបំបែកកិច្ចដំណើរការនីតិវិធី[3] អង្គជំនុំជម្រះបានធ្វើការសង្កេតថា៖

> ... *មិនបានច្រានចោលលទ្ធភាពនៃការបញ្ចូលបន្ថែមបទចោទទៅក្នុងសវនាការជំនុំជម្រះលើកទីមួយក្នុងសំណុំរឿង ០០២ ទេ បើសិនជាកាលៈទេសៈអនុញ្ញាត។ អង្គជំនុំជម្រះកត់សម្គាល់នូវការចង្អុលបង្ហាញរបស់សហព្រះរាជអាជ្ញានៅក្នុងសំណើសុំរបស់ខ្លួនអំពីបញ្ហាបន្ថែមដែលអាចមានសម្រាប់ដាក់បញ្ចូលនៅក្នុងការជំនុំជម្រះដំណាក់កាលដំបូង ហើយអង្គជំនុំជម្រះត្រូវបានណែនាំដោយការយល់ឃើញរបស់សហព្រះរាជអាជ្ញាថាជាការចោទប្រកាន់ជាអាទិភាព សម្រាប់ធ្វើការពិចារណាក្នុងអំឡុងដំណាក់កាលនៃការជំនុំជម្រះក្រោយៗទៀត...*[4]។

៣- នៅក្នុងកិច្ចប្រជុំគ្រប់គ្រងសវនាការក្រៅផ្លូវការ នៅថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១១ មន្ត្រីជាន់ខ្ពស់ទទួលបន្ទុកកិច្ចការច្បាប់បានបញ្ជាក់ក្នុងនាមអង្គជំនុំជម្រះថា អង្គជំនុំជម្រះនៅតែបើកចំហរ នៅក្នុងការពង្រីក

[1] **E124** ដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី អនុលោមតាមវិធាន៨៩*ស្ទួនពីរ* នៃវិធានផ្ទៃក្នុង", ២២ កញ្ញា ២០១១ ("ដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី")។

[2] **E124** *ដដែលដូចខាងលើ* ត្រង់កថាខ័ណ្ឌទី ៦។

[3] **E124/7** សេចក្ដីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញា សុំឱ្យពិចារណាឡើងវិញអំពីលក្ខខណ្ឌនានានៃដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធីរបស់អង្គជំនុំជម្រះសាលាដំបូង (ឯកសារ E124/2) និងសំណើសុំពាក់ព័ន្ធនានា ព្រមទាំងឧបសម្ព័ន្ធ, ១៨ តុលា ២០១១ ត្រង់កថាខ័ណ្ឌទី ១២ ។

[4] **E124/7** *ដដែលដូចខាងលើ* ត្រង់កថាខ័ណ្ឌទី ១២។

វិសាលភាពនៃសវនាការលើកទីមួយ តាមរយៈការដាក់បញ្ចូលទីតាំងឧក្រិដ្ឋកម្មបន្ថែម និងអង្គហេតុចោទប្រកាន់នានា បើសិនកាលៈទេសៈអនុញ្ញាត[5]។

៤- សហព្រះរាជអាជ្ញាសូមស្នើដោយគោរពដល់អង្គជំនុំជម្រះដាក់បញ្ចូលទីតាំងឧក្រិដ្ឋកម្ម និងអង្គហេតុចោទប្រកាន់ទាំងប៉ុន្មានដូចខាងក្រោមនេះ ដែលយកចេញពីដំណោះស្រាយ ទៅក្នុងវិសាលភាពនៃសំណុំរឿង ០០២/១៖

(ក) ការសម្លាប់អ្នកជម្លៀស ១៧ មេសា ១៩៧៥ នៅទីតាំងសម្លាប់មនុស្សកំពង់ត្រឡាចលើ (ស្រុក១២) ខេត្តកំពង់ឆ្នាំង (តំបន់៣១ នៃភូមិភាគបស្ចិម) (កថាខ័ណ្ឌទី៦៩១, ៦៩៣-៦៩៧ នៃដីកាដំណោះស្រាយ)។

(ខ) ការសម្លាប់អតីតយោធា និងមន្ត្រីរបស់ លន់ ណល់ ក្នុងឆ្នាំ១៩៧៥ ទីតាំងសម្លាប់មនុស្សនៅទួលពោធិ៍ជ្រៃ ស្រុកកណ្ដៀង ខេត្តពោធិ៍សាត់ (តំបន់៧ នៃភូមិភាពាយ័ព្យ) (កថាខ័ណ្ឌទី៦៩៨-៧១១ នៃដីកាដំណោះស្រាយ;

(គ) មន្ទីរសន្តិសុខ ស-២១ និងទីតាំងសម្លាប់មនុស្សដែលពាក់ព័ន្ធនៅជើងឯក ខេត្តកណ្ដាល (កថាខ័ណ្ឌទី៤១៥-៤៧៥ នៃដីកាដំណោះស្រាយ) *រួមទាំង* ការបោសសម្អាតកម្មាភិបាលមកពីភូមិភាគឧត្តរថ្មី ភូមិភាគកណ្ដាល(ឧត្តរចាស់) និងភូមិភាគបូព៌ា ដែលបានបញ្ជូនទៅមន្ទីរស-២១ (កថាខ័ណ្ឌទី១៩២-២០៤ នៃដីកាដំណោះស្រាយ) ប៉ុន្តែ *មិនរាប់បញ្ចូល* ការដ្ឋានព្រៃស ក្នុងស្រុកដង្កោរ ខេត្តកណ្ដាលទេ។

៥- ទីតាំងឧក្រិដ្ឋកម្មទាំងនេះ គ្រាន់តែឆ្លុះបញ្ចាំងទីតាំងឧក្រិដ្ឋកម្មបីកន្លែង ក្នុងចំណោមទីតាំងឧក្រិដ្ឋកម្មទាំងប្រាំបួនកន្លែងដែលបានស្នើពីដំបូងដោយសហព្រះរាជអាជ្ញា ដើម្បីដាក់បញ្ចូលទៅក្នុងសវនាការដំបូងនេះ[6]។ សហព្រះរាជអាជ្ញាសន្និដ្ឋានថា ការបញ្ចូលអង្គហេតុចោទប្រកាន់ទាំងនេះ គឺជាការចាំបាច់ក្នុងប្រយោជន៍នៃយុត្តិធម៌ និងថាលក្ខណៈវិនិច្ឆ័យដែលពាក់ព័ន្ធទៅនឹងការវាយតម្លៃរបស់អង្គជំនុំ

[5] កំណត់សំគាល់របស់តំណាង កសព បង្ហាញនៅថ្ងៃទី២ ធ្នូ ២០១១ ក្នុងកិច្ចប្រជុំគ្រប់គ្រងសវនាការក្រៅផ្លូវ។

[6] **E124/2** សំណើរបស់សហព្រះរាជអាជ្ញា សុំឲ្យពិចារណាឡើងវិញចំពោះ "ដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី អនុលោមតាមវិធាន *៨៩ស្ទួនពីរ*", ៣ តុលា ២០១១ ត្រង់កថាខ័ណ្ឌទី៣៦-៤៤។

ជម្រះទាក់ទងនឹងការណ៍នេះ គួររាប់បញ្ចូលទាំងៈ (i) តាមលទ្ធភាពអាចធ្វើទៅបានមានផលប្រយោជន៍តាមកាលប្បវត្តិ និងតក្កនៃដីកាដំណោះស្រាយ (ii) គុណភាព និងភាពគ្រប់គ្រាន់នៃភ័ស្តុតាង (iii) តម្រូវការចាំបាច់តំណាងសមហេតុផលវិសាលភាពអង្គហេតុនៅក្នុងសវនាការ។

៦- ជាការបន្ថែម សហព្រះរាជអាជ្ញាសន្និដ្ឋានថា ការពន្យារដូចបានស្នើឡើងនៅក្នុងវិសាលភាពនៃការជំនុំជម្រះនឹងបំពេញបានព្រមទាំងលើសពីបទដ្ឋាននីតិវិធីអន្តរជាតិ ទាក់ទងនឹងកិច្ចដំណើរការនីតិវិធីដែលពាក់ព័ន្ធនឹងពេលវេលាគ្រប់គ្រាន់ សម្រាប់ការត្រៀមរៀបចំនូវកិច្ចការពារឲ្យបានប្រសិទ្ធភាព និងការជូនដំណឹងដល់គូភាគីនានាឲ្យបានទាន់ពេលវេលា។

៧- ជាចុងក្រោយ សហព្រះរាជអាជ្ញាសន្និដ្ឋានថា សេចក្តីសម្រេចណាមួយដើម្បីពន្យារវិសាលភាពនៃសវនាការជំនុំជម្រះក្តីអាចធ្វើបាន និងគួរតែបានធ្វើនៅពេលនេះ មុនពេលបញ្ចប់ផ្នែកនៃកិច្ចដំណើរការនីតិវិធីនេះ ពាក់ព័ន្ធទៅនឹងប្រវត្តិសាវតា។ ការណ៍នេះនឹងជួយសម្រួលដល់ការត្រៀមរៀបចំផ្សេងៗឲ្យកាន់តែមានប្រសិទ្ធិភាពដោយគូភាគីទាំងអស់ តាមរយៈការធ្វើឲ្យសម្រេចបាននូវការបង្ហាញភ័ស្តុតាងផ្សេងៗក្នុងលក្ខណៈមួយជារចនាសម្ព័ន្ធ និងដែលបានបញ្ចូលគ្នាយ៉ាងល្អ ធ្វើឲ្យការប្រើប្រាស់កាន់តែមានប្រសិទ្ធិភាពនូវពេលវេលាសម្រាប់សួរសំណួរផ្សេងៗចំពោះសាក្សី ដែលអាចជាអ្នកផ្តល់នូវភ័ស្តុតាងដ៏មានសក្តានុពល ពាក់ព័ន្ធនឹងការបង្ហាញឲ្យឃើញអំពីឈុតនៃឧក្រិដ្ឋកម្មដ៏ធំធេងកាន់តែច្បាស់ថែមទៀត ព្រមទាំងគោលនយោបាយនានាដែលមានលក្ខណៈពង្រីកវិសាលភាពយ៉ាងទូលំទូលាយនៃសហកម្មឧក្រិដ្ឋកម្មរួមដូចបានចោទប្រកាន់ ដូច្នេះនឹងកាត់បន្ថយជាអប្បបរមានូវតម្រូវការសម្រាប់ការកោះហៅជាថ្មីឡើងវិញនូវសាក្សីណាម្នាក់។

## II. ការពង្រីកវិសាលភាពសវនាការជំនុំជម្រះដូចដែលបានស្នើឡើង នឹងបានជាប្រយោជន៍នៃយុត្តិធម៌

### *ក. ការដាក់បញ្ចូលទីតាំងឧក្រិដ្ឋកម្មដែលបានស្នើឡើងឆ្លុះបញ្ចាំងតក្ក និងកាលប្បវត្តិនៅក្នុងដីកាដំណោះស្រាយ*

៨- អង្គជំនុំជម្រះបានបញ្ជាក់ថា សំណុំរឿង ០០២/១ នឹងមានដំណាក់ទីមួយ និងទីពីរ នៃការជម្លៀសប្រជាជន ព្រមទាំងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិលាក់ផ្សេងៗទៀតឲ្យតែ ឧក្រិដ្ឋកម្មទាំងនោះជាប់ពាក់ព័ន្ធទៅនឹងការជម្លៀសប្រជាជនដែលពាក់ព័ន្ធនឹងដំណាក់កាលទាំងពីរនេះ[7]។ អង្គជំនុំជម្រះក៏បានថ្លែងផងដែរថា ដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធីបំរើឲ្យគោលបំណង "ដើម្បីអនុវត្តឲ្យបានតាមដែលអាចធ្វើទៅបាន នូវកាលប្បវត្តិ និង/ឬ យថាក្រមនៃដីកាដំណោះស្រាយ..."[8]។ សហព្រះរាជអាជ្ញាសូមធ្វើការសន្និដ្ឋានដោយគោរពថា ដោយមានការពិចារណាអំពីយថាក្រម និងកាលប្បវត្តិនៃព្រឹត្តិការណ៍នានាដែលមាននៅក្នុងដីកាដំណោះស្រាយ ទីតាំងសម្លាប់មនុស្សនៃស្រុក១២ និងទួលពោធិ៍ជ្រៃ ហើយនិងមន្ទីរសន្តិសុខ ស-២១ គួរតែបានដាក់បញ្ចូលក្នុងវិសាលភាពនៃសំណុំរឿង ០០២/១ ដោយសារមូលហេតុដូចខាងក្រោម។

៩- សក្ខីកម្មរបស់សាក្សីអះអាងបញ្ជាក់ថានៅក្នុងរយៈពេលមួយខែទៅពីរខែ ភ្លាមៗនៅក្រោយថ្ងៃទី១៧ មេសា ១៩៧៥ អ្នកដែលត្រូវបានគេជម្លៀសពីភ្នំពេញ និងទីប្រជុំជនខេត្តកំពង់ឆ្នាំង និងជាអ្នកដែលត្រូវបានគេកំណត់អត្តសញ្ញាណថា អតីតទាហាននិងមន្ត្រីនៃសាធារណៈរដ្ឋខ្មែរ ត្រូវបានគេសម្លាប់ចោលនៅទីតាំងសម្លាប់មនុស្សស្រុក១២ នេះ[9]។ ជាការបន្ថែម ភ្លាមៗបន្ទាប់ពី "ការរំដោះ" ភ្នំពេញ ទាហាន និងមន្ត្រីនៃរបប លន់ នល់ ត្រូវបានហ៊ុំពាត់ និងសម្លាប់ចោលនៅទីតាំងសម្លាប់មនុស្សទួលពោធិ៍ជ្រៃ[10]។ ក្នុងចំណោមទីតាំងសម្លាប់មនុស្សទាំងនេះ នៅទីតាំងទួលពោធិ៍ជ្រៃតែមួយ គេបានប៉ាន់ស្មានថា មានមនុស្សស្លាប់ចន្លោះពី ២០០០ទៅ ៣០០០នាក់[11] ដែលបានកើតឡើងភ្លាមៗនៅក្រោយពេលដែល បកក បានចូលកាន់កាប់ទីក្រុងភ្នំពេញ និងជាលទ្ធផលដោយផ្ទាល់ចេញពីការជម្លៀសប្រជាជនភ្នំពេញ និងទីក្រុងដទៃទៀត ដែលនៅក្នុងពេលនោះខ្មាំងរបស់បក្ស ត្រូវបានគេកំណត់អត្តសញ្ញាណ និងលុបបំបាត់។

---

[7] **E124/7.2** ឧបសម្ព័ន្ធ: បញ្ជីកថាខ័ណ្ឌ និងចំណែកខ្លះនៃដីកាដំណោះស្រាយ ដែលពាក់ព័ន្ធនឹងសវនាការទីមួយ ក្នុងសំណុំរឿង ០០២, ដែលបានកែប្រែបន្ថែមទៅតាមសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ស្ដីពីសម្បទាក្នុងការចូលរួមសវនាការរបស់ អៀង ធីរិទ្ធ, ៣០ វិច្ឆិកា ២០១១។

[8] **E124/7** កំណត់សំគាល់*ខាងដើម* លេខ៣ ត្រង់កថាខ័ណ្ឌទី១០។

[9] **D427** ដីកាដំណោះស្រាយ, ១៥ កញ្ញា ២០១០, ត្រង់កថាខ័ណ្ឌទី៦៩១។

[10] **D427** *ដដែលដូចខាងលើ,* ត្រង់កថាខ័ណ្ឌទី៧០៩-៧១០។

[11] **D427** *ដដែលដូចខាងលើ,* ត្រង់កថាខ័ណ្ឌទី៧១១។

១០- ការសម្រេចចិត្តក្នុងការបង្កើតមន្ទីរសន្តិសុខស-២១ ត្រូវបានគេធ្វើឡើងក្នុងពេលប្រជុំមួយនៅទីក្រុងភ្នំពេញនៅថ្ងៃទី១៥ សីហា ១៩៧៥[12] ដែលមន្ទីរនេះបានធ្វើប្រតិបត្តិការរបស់ខ្លួនពេញលេញក្នុងខែតុលា ១៩៧៥[13]។ ការបង្កើតមន្ទីរសន្តិសុខស-២១ បង្កើតបានជាផ្នែកមួយនៃគោលនយោបាយរបស់ បកក ក្នុងការប្រើអំពើហិង្សាដើម្បីលប់បំបាត់ខ្មាំង ដែលជាគោលនយោបាយមួយត្រូវបានគេអភិវឌ្ឍន៍ឡើងតាំងពីសមាជបក្សលើកទីមួយ ឆ្នាំ១៩៦០ មកម្ល៉េះ។ ស-២១ ជាស្នូលដ៏សំខាន់ដើម្បីសម្រេចបានពិតប្រាកដនូវគោលនយោបាយនេះ និងបានប្រើការជាស្ថាប័នគន្លឹះរបស់ បកក ចាប់ពីខែតុលា ១៩៧៥ តទៅដោយការរាយការណ៍ជូនថ្នាក់ខ្ពស់បំផុតរបស់បក្ស[14]។ ការសម្រេចជម្លៀសប្រជាជនភ្នំពេញត្រូវបានគេលើកមូលដ្ឋានមកសំអាងថា គឺដើម្បីលាងសំអាងទីក្រុង អាចឲ្យបក្សកំណត់អត្តសញ្ញាណ "ខ្មាំង" និងលប់បំបាត់ពួកទាំងនោះនៅតាមមន្ទីរសន្តិសុខ និងទីតាំងសម្លាប់មនុស្សនានា។ ក្នុងសំណុំរឿង ០០១ ឌុច បានផ្តល់សក្ខីកម្មថា:

> *... ប្រជាជនថ្មី ឬ ប្រជាជន១៧មេសា ... គ្មានសិទ្ធិទេ* [...]។ *ប្រជាជនដែលបានបញ្ជូនទៅស-២១ គឺបក្សបានចាត់ទុកពួកគេថា ជាខ្មាំងរួចហើយ ហើយចំពោះខ្មាំង ពួកគេត្រូវតែបានកម្ទេច*[15]។

១១- ទន្ទឹមនេះដែរ ឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនៅស-២១ ដែលបានកើតឡើងតាំងពីដើមឆ្នាំ១៩៧៥ មកក៏មានជាប់ជំពាក់ដោយផ្ទាល់ទៅនឹងសេចក្តីសម្រេចផ្សេងៗ និងការអនុវត្តគោលនយោបាយនៃការជម្លៀសដោយបង្ខំផងដែរ។ ទីតាំងឧក្រិដ្ឋកម្មទាំងបីដែលបានស្នើឡើងនេះ គឺបានធ្វើប្រតិបត្តិការក្នុងឆ្នាំ១៩៧៥ ពេលដែលឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដូចដែលបានចោទប្រកាន់ គឺជាលទ្ធផលដែលបានកើតចេញពីការជម្លៀសប្រជាជនដែលបានកើតឡើងនោះ។ ដោយឈរលើមូលដ្ឋាននេះ សហព្រះរាជអាជ្ញាសូមស្នើដោយគោរពសុំឲ្យដាក់បញ្ចូលទីតាំងក្រិដ្ឋកម្មដូចបានស្នើឡើងនេះ ដើម្បីបានជាប្រយោជន៍នៃយុត្តិធម៌ ដោយគិតគូរអំពីយថាក្រម និងកាលប្រវត្តិនៃដីកាដំណោះស្រាយ។

---

[12] **D427** *ដដែលដូចខាងលើ,* ត្រង់កថាខ័ណ្ឌទី៤១៦។

[13] **D427** *ដដែលដូចខាងលើ,* ត្រង់កថាខ័ណ្ឌទី៤១៦។

[14] **D427** *ដដែលដូចខាងលើ,* ត្រង់កថាខ័ណ្ឌទី៤២២។

[15] ប្រតិចារិកនៃដំណើរការនីតិវិធីសួរជនជាប់ចោទកាំង ហ្គិចអ៊ាវ ហៅឌុច សំណុំរឿង០០១ ចុះថ្ងៃទី១៨-០៧-២០០៧។

១២- នៅក្នុងការវាយតម្លៃថាតើវិសាលភាពនៃសវនាការមានកម្រិតប៉ុណ្ណានោះ ក្នុងផលប្រយោជន៍យុត្តិធម៌ សហព្រះរាជអាជ្ញាសន្និដ្ឋានថា អង្គជំនុំជម្រះសាលាដំបូងគួរពិចារណាផងដែរអំពីគុណភាព និងភាពគ្រប់គ្រាន់នៃភស្តុតាង ដែលជាប់ទាក់ទងទៅនឹងទីតាំងឧក្រិដ្ឋកម្មបន្ថែមដែលបានស្នើឡើងទាំងនេះ។

១៣- ភស្តុតាងនៃទីតាំងឧក្រិដ្ឋកម្មសម្រាប់មន្ទីរសន្តិសុខស-២១ និងជើងឯក ត្រូវបានចងក្រងជាឯកសារយ៉ាងល្អ។ នៅក្រោមរបបកម្ពុជាប្រជាធិបតេយ្យ ទីតាំងទាំងនេះជាឧបករណ៍នៅក្នុងពង្រីកការអនុវត្តផែនការឧក្រិដ្ឋរបស់ បកក ចាប់ពីថ្នាក់មេដឹកនាំ ដើម្បីលុបបំបាត់ជាប្រព័ន្ធនូវជនណាដែលគេយល់ថាជាខ្មាំង និងខ្មាំងពិតប្រាកដ និងការបោសសម្អាតចំពោះកម្លាំងប្រឆាំងនឹងបក្សនេះ។ ដីកាដំណោះស្រាយ មានភស្តុតាង៧២កថាខ័ណ្ឌ ដែលជាប់ទាក់ទងនឹងមន្ទីរស-២១, ជើងឯក និងការបោសសម្អាតកម្មាភិបាលទាំងឡាយ រួមមានអ្នកដែលគេបញ្ជូនមកពីភូមិភាគឧត្តរថ្មី ភូមិភាគកណ្តាល(ឧត្តរចាស់) និងភូមិភាគបូព៌ាដែលបានបញ្ជូនទៅ ស-២១[16]។ ការចោទប្រកាន់ក្នុងចំណែកទាំងនេះនៃដីកាដំណោះស្រាយ គឺមានបញ្ជាក់យ៉ាងត្រឹមត្រូវដោយមានការយោងទៅលើឯកសារ និងកំណត់ហេតុផ្សេងៗដែលបានផ្តល់ជូនសហចៅក្រមស៊ើបអង្កេត[17]។ ដីកាដំណោះស្រាយចែងថា មន្ទីរស-២១ គឺជា "ស្ថាប័នមួយរបស់បក្សកុម្មុយនីស្តកម្ពុជា [ហើយ] ការគ្រប់គ្រងស្ថាប័ននេះបានរាយការណ៍ទៅថ្នាក់លើបំផុតរបស់បក្ស[18]។ ឌុច បានផ្តល់សក្ខីកម្មអំពីប្រសិទ្ធនៃការត្រួតត្រារបស់គណៈអចិន្ត្រៃយ៍ទៅលើប្រតិបត្តិការនៃមន្ទីរស-២១។ ក្នុងសាលក្រមសំណុំរឿង ០០១ អង្គជំនុំជម្រះនេះបានទទួលស្គាល់អំពីភាពសំបូរណ៍បែបនៃអង្គហេតុជុំវិញឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងនៅ ស-២១ និងជើងឯក[19]។ សាលក្រមនេះក៏បានយោងផងដែរទៅលើ "បរិបទប្រវត្តិសាស្ត្រ និងនយោបាយនៃរចនាសម្ព័ន្ធ និងគោលនយោបាយរបស់ បកក ជាពិសេស ចំពោះប្រតិបត្តិការរបស់មន្ទីរ ស-២១"[20]។ ក្នុងស្មារតីនៃមូលដ្ឋានភស្តុតាងដ៏រឹងមាំចំពោះឧក្រិដ្ឋកម្មដែលបានកើតឡើង នៅទីតាំងឧក្រិដ្ឋកម្ម ស-២១ និងជើងឯក វាជា

[16] សូមអាន **D427** ដីកាដំណោះស្រាយ ត្រង់កថាខ័ណ្ឌទី 192-204, 415-475 (FN 1806-2045, 637-697)។

[17] សូមអាន **D427** *ដដែលដូចខាងលើ* ត្រង់កំណត់សំគាល់ចុងទំព័រទី 637-697, 1806-2045 ។

[18] **D427** *ដដែលដូចខាងលើ* ត្រង់កថាខ័ណ្ឌទី ៤២២។

[19] E188 សំណុំរឿង/Dossier លេខ: 001/18-07-2007/ECCC/TC, **E188**, **កាំង ហ្កេកអ៊ាវ ហៅ ឌុច**, សាលក្រម, ២៦ កក្កដា ២០១០ ត្រង់កថាខ័ណ្ឌទី ៤២-៧២។

[20] *ដដែលដូចខាងលើ* ។

ប្រយោជន៍យុត្តិធម៌ដែលត្រូវពង្រីកវិសាលភាពសវនាការដំបូង ដោយរួមបញ្ចូលទាំងទីតាំងឧក្រិដ្ឋកម្មទាំងនេះ។

១៤- ក៏មានការទាក់ទងគ្នាដ៏សំខាន់នៃភស្តុតាងផងដែរ រវាងទីតាំងឧក្រិដ្ឋកម្មដែលបានស្នើសុំ នៅក្នុងស្រុក១២ និងទួលពោធិ៍ជ្រៃ និងអង្គហេតុនានាដែលផ្សារភ្ជាប់ទៅនឹងប្រវត្តិដើម និងទៅនឹងជំហានទីមួយនៃការជម្លៀសប្រជាជន ដែលជាចំណុចដែលសវនាការជំនុំជម្រះក្តីលើកដំបូងបានផ្តោតលើ។ នៅក្នុងដីកាដំណោះស្រាយ សហចៅក្រមស៊ើបអង្កេតបានរកឃើញថា ទីកន្លែងសម្លាប់នៅស្រុកកំពង់ត្រឡាចលើ(ស្រុក១២) នៅក្នុងខេត្តកំពង់ឆ្នាំង ត្រូវបានបង្កើតឡើងដោយពួកកម្មាភិបាល បកក មុនពេលទីក្រុងភ្នំពេញបានដួលរលំនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ហើយដែលថែមទាំងត្រូវបានបំរើការជាទីបញ្ជាការរបស់បកក មុនឆ្នាំ១៩៧៥ទៀតផង[21]។ ការសម្លាប់ពួកជម្លៀសនៅស្រុក១២ គឺជាឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងយ៉ាងជាក់លាក់ ដែលជាផ្នែកមួយនៃការជម្លៀសដោយបង្ខំដំណាក់កាលទីមួយ ដែលជាការបន្ថែមទៅនឹង គោលបំណងរបស់ បកក ក្នុងការកំណត់អត្តសញ្ញាណ និងកំទេចពួកខ្មាំងដែលបានដកចេញពីទីក្រុងនានា។ កន្លែងសម្លាប់មនុស្សទួលពោធិ៍ជ្រៃបានក្លាយទៅជាកិច្ចប្រតិបត្តិការនៅក្នុងរយៈកាល ឬភ្លាមៗបន្ទាប់ពីការជម្លៀសប្រជាជនដោយបង្ខំដំណាក់កាលទីមួយ[22]។ ពួកជនរងគ្រោះចម្បងនៃឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនៅតាមទីតាំងទាំងនេះ ក្នុងរយៈកាលភ្លាមៗបន្ទាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ គឺពួកទាហាន មន្ត្រីផ្លូវការ និងពួករដ្ឋការស៊ីវិលនៃរបបសាធារណរដ្ឋខ្មែរ[23]។

## *ខ. ការជ្រើសរើស និងការកំណត់អាទិភាពនៃទីតាំងឧក្រិដ្ឋកម្មនានា នៅក្នុងសវនាការលើកដំបូង គួរតែបានបង្ហាញសមហេតុសមផលអំពីការប្រព្រឹត្តបទឧក្រិដ្ឋនានាដែលបានចោទប្រកាន់*

១៥- ដីកាសម្រេចស្តីពីការបំបែកកិច្ចដំណើរការនីតិវិធី និងសេចក្តីសម្រេចក្នុងការបដិសេធសំណើរបស់សហព្រះរាជអាជ្ញាដែលសុំឲ្យពិនិត្យពិចារណាឡើងវិញ គឺស្ថិតនៅលើការសន្មតថា ដំណាក់កាលជាបន្តទៅទៀតនៃសំណុំរឿងលេខ០០២ តាមការពិត នឹងត្រូវបានធ្វើឡើងតទៅទៀត។ ហេតុដូចនេះ អង្គជំនុំជម្រះយល់ឃើញថា “មិនចាំបាច់ឲ្យសវនាការលើកដំបូង ធ្វើការបង្ហាញសមហេតុសមនៃការ

[21] **D427** *កំណត់សំគាល់ខាងដើម* លេខ៩ ត្រង់កថាខ័ណ្ឌទី 687-697។

[22] **D427** *ដដែលដូចមុន* ត្រង់កថាខណ្ឌទី ៦៩៨-៧១៤។

[23] **D427** *ដដែលដូចមុន* ។

ចោទប្រកាន់ទាំងអស់ដែលមាននៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះនោះទេ”[24]។

ចាប់តាំងពីពេលនោះមក អៀង ធីរិទ្ធ ត្រូវបានគេប្រកាសថា មិនមានសម្បទាគ្រប់គ្រាន់ដើម្បីអាចចូលរួមនៅក្នុងសវនាការបានទេ[25]។ កិច្ចដំណើរនៃសវនាការជំនុំជម្រះក្តីត្រូវបានលើកពេល ឬត្រូវបានកំណត់កាលបរិច្ឆេទសាជាថ្មីឡើងវិញ តាមរយៈការជូនដំណឹងក្នុងពេលដ៏ខ្លីបំផុត ដោយសារតែមានការព្រួយបារម្ភចំពោះសុខភាពរបស់ នួន ជា[26], សាក្សី[27], និងដើមបណ្តឹងរដ្ឋប្បវេណីនានា[28]។

១៦- សហព្រះរាជអាជ្ញានៅតែមានការព្រួយបារម្ភជាដដែលថា ការជំនុំជម្រះក្តីដំណាក់កាលដំបូងនៅក្នុងសំណុំរឿងលេខ០០២ ដែលទាក់ទងនឹងការជម្លៀសប្រជាជនចេញនេះ អាចបង្កើតជាកេរ្តិ៍ដំណែលរបស់អង្គជំនុំជម្រះនេះ សម្រាប់ប្រជាជនកម្ពុជា។ ក្នុងស្មារតីនេះ ឥទ្ធិពលនៃដីកាបំបែកកិច្ចដំណើរការនីតិវិធី គឺដូចគ្នាបេះបិទទៅនឹងការជ្រើសរើសករណីរឿង ដើម្បីធ្វើការជំនុំជម្រះ ដូចដែលបានកើតឡើងនៅតុលាការ ICC និងតុលាការ ICTY ដែរ។ ការជ្រើសរើសករណីរឿង និងការកំណត់អាទិភាពគឺមានផលប៉ះពាល់ដោយផ្ទាល់ដល់ការបំពេញ ឬម៉្យាងទៀតដល់ វត្ថុបំណង និងគោលបំណងនៃ *កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជានូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ(“កិច្ចព្រមព្រៀង”)*។ នៅក្នុងបុព្វកថានៃកិច្ចព្រមព្រៀងនេះបានចែងថា “*មហាសន្និបាតបានទទួលស្គាល់ការព្រួយបារម្ភពេញច្បាប់របស់រដ្ឋាភិបាល និងប្រជាជនកម្ពុជា ក្នុងការស្វែងរកយុត្តិធម៌ការបង្រួបបង្រួមជាតិ ស្ថេរភាព សន្តិភាព និងសន្តិសុខ*”[29]។ អាស្រ័យហេតុនេះ ការស្វែងរកយុត្តិធម៌ការបង្រួបបង្រួមជាតិ ស្ថេរភាព សន្តិភាព និងសន្តិសុខនៅក្នុងប្រទេសកម្ពុជា គឺជាគោលដៅដ៏សំខាន់ដែលជាមគ្គុទេសន៍នាំផ្លូវដល់ការងាររបស់ អវតក។ ការផ្តល់នូវការរៀបរាប់រឿងរ៉ាវផ្សេងៗអំពីប្រវត្តិសាវតាពិតនៃឧក្រិដ្ឋកម្មនានាដែលបានប្រព្រឹត្តនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ (“DK”) គឺជាប្រការ

---

[24] **E124/7** *កំណត់សំគាល់ខាងលើ* លេខ៣ ត្រង់កថាខ័ណ្ឌទី៩។

[25] **E138** សេចក្តីសម្រេចអំពីសម្បទាចូលរួមក្នុងសវនាការរបស់ អៀង ធីរិទ្ធ, ១៧ វិច្ឆិកា ២០១១។

[26] ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធីសវនាការ, សំណុំរឿងលេខ: 002/19-09-2007-ECCC/TC, 5 & 6 ធ្នូ ២០១១។

[27] ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធីសវនាការ, សំណុំរឿងលេខ: 002/19-09-2007-ECCC/TC, ៩ ធ្នូ ២០១១។

[28] ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធីសវនាការ, សំណុំរឿងលេខ: 002/19-09-2007-ECCC/TC, ៧ ធ្នូ ២០១១។

[29] កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ ជាមួយរាជរដ្ឋាភិបាលកម្ពុជា ពាក់ព័ន្ធនឹងការផ្តន្ទាទោសនៅក្រោមច្បាប់កម្ពុជា នូវឧក្រិដ្ឋកម្មទាំងឡាយដែលបានប្រព្រឹត្តនៅក្នុងសម័យកាលកម្ពុជាប្រជាធិបតេយ្យ, ៦ មិថុនា ២០០៣ ត្រង់ទំព័រទី១។

សំខាន់ចាំបាច់សម្រាប់គោលដៅទាំងនេះ[30]។ ភាពត្រឹមត្រូវនៃកំណត់ហេតុប្រវត្តិសាស្ត្រអាចនឹងដំណើរការទៅមុខក្នុងលក្ខណៈជាដុំកំភួនបាន បើសិនជាសវនាការលើកដំបូងនេះបានធ្វើការបង្ហាញសមស្របនៃឧក្រិដ្ឋកម្មទាំងឡាយដែលបានប្រព្រឹត្តនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ[31]។

១៧- ការជ្រើសរើស និងការកំណត់អាទិភាពនៃករណីរឿង មានផលប៉ះពាល់តាមវិធីដែលដំណើរការយុត្តិធម៌ត្រូវបានទទួលដោយជនរងគ្រោះ និងជនដទៃទៀតដែលបានរងផលប៉ះពាល់ដោយអំពើដ៏សាហាវព្រៃផ្សៃនានា[32]។ វាក៏អាចប៉ះពាល់ដល់ភាពត្រឹមត្រូវតាមច្បាប់ដែលត្រូវបានយល់ដឹងដោយអារម្មណ៍ ដោយរដ្ឋនានា និងសហគមន៍អន្តរជាតិ[33]។ ឧទាហរណ៍ដូចជា អ្នកធ្វើសេចក្តីអត្ថាធិប្បាយស្តីពីការងាររបស់តុលាការអន្តរជាតិដែលទទួលការគោរព បានសង្កេតឃើញថាការចោទប្រកាន់ដែលមានលក្ខណៈតូចចង្អៀត(ការជ្រើសរើសកុមារចូលឱ្យបំរើជាយោធា) ដែលត្រូវបានបញ្ជាក់អះអាងប្រឆាំងនឹងឈ្មោះ Thomas Lubanga Dyilo បានធ្វើឱ្យខូចដល់ការយល់ដឹងដោយអារម្មណ៍អំពីតុលាការនោះ[34]។ គេអាចទាញចេញជាភាពស្របគ្នាមួយចំនួនជាមួយនឹងស្ថានភាពបច្ចុប្បន្ននៅចំពោះមុខ អវតក។ សវនាការជំនុំជម្រះក្តីលើកដំបូងនាពេលបច្ចុប្បន្ននេះរួមមានតែដំណាក់កាលទីមួយទាំងពីរលើកនៃការជម្លៀសប្រជាជនចេញពីក្រុងភ្នំពេញតែប៉ុណ្ណោះ។ នេះគឺជាសញ្ញាដែលកត់សម្គាល់ពីភាពផ្ទុយគ្នាទៅនឹងក្រុមនៃទីតាំងឧក្រិដ្ឋកម្មនានាដែលមានទំហំធំជាងនេះ ដែលក្នុងនោះរួមមានឧក្រិដ្ឋកម្មសំខាន់ដែលមានស្ថានទម្ងន់ធ្ងន់ជាងឧក្រិដ្ឋកម្មដែលបានដាក់បញ្ចូលបច្ចុប្បន្ននេះ នៅក្នុងសវនាការលើកដំបូង។ ទីតាំងឧក្រិដ្ឋកម្មទាំងបីដែលបានស្នើឡើងនេះ មានពាក់ព័ន្ធទៅនឹងអំពើសម្លាប់មនុស្សដែលបានកំណត់បទចោទថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅក្នុងដីកាដំណោះស្រាយ[35]។

---

[30] Anees Ahmed និង Margaux Day, *លក្ខណៈវិនិច្ឆ័យសម្រាប់ការផ្តន្ទាទោស នៅសាលាក្តីខ្មែរក្រហម,* ការបោះពុម្ពផ្សាយលេខ ៤, (២០១០, ការបោះពុម្ពផ្សាយលើកទីពីរ) ត្រង់ទំព័រ១១៥។

[31] *ដដែលដូចខាងលើ។*

[32] Morten Bergsmo, *គម្រោងលក្ខណៈវិនិច្ឆ័យសម្រាប់ការជ្រើសរើស និងការផ្តល់អាទិភាព និងថា ហេតុអ្វីបានជាពាក់ព័ន្ធ, (The Theme of Selection and Prioritization Criteria and Why it Is Relevant),* ការបោះពុម្ពផ្សាយ ភាគ៤ របស់ FICHL (២០១០, ការបោះពុម្ពផ្សាយលើកទីពីរ) ត្រង់ទំព័រ៩។

[33] *ដដែលដូចខាងលើ។*

[34] Richard Dicker, *ធ្វើឱ្យយុត្តិមានអត្ថន័យសម្រាប់ជនរងគ្រោះ,* ការបោះពុម្ពផ្សាយ ភាគ៤ របស់ FICHL (២០១០, ការបោះពុម្ពផ្សាយលើកទីពីរ) ត្រង់ទំព័រ២៧០។

[35] *សូមអាន* កថាខ័ណ្ឌទី ២០ ខាងក្រោម។

១៨- សវនាការលើកដំបូងនាពេលបច្ចុប្បន្ននេះក៏បានដកចេញផងដែរនូវទីតាំងឧក្រិដ្ឋកម្មនានា ដែលមានការជាប់ទាក់ទងខាងក្នុងជាមួយនឹងដំណាក់កាលទីមួយ នៃការជម្លៀសប្រជាជនចេញដោយបង្ខំពីទីក្រុងភ្នំពេញ។ ដើម្បីឱ្យឈានទៅដល់ការវាយតម្លៃរបស់តុលាការមួយដ៏ត្រឹមត្រូវអំពីការជម្លៀសប្រជាជនចេញដោយបង្ខំ អង្គជំនុំជម្រះគួរតែពិចារណាទៅលើឧក្រិដ្ឋកម្មជាក់លាក់ទាំងអស់ដែលបានចោទប្រកាន់ពាក់ព័ន្ធទៅនឹងអង្គហេតុទាំងនេះ។ ការសម្លាប់អ្នកជម្លៀស និងអតីតយោធា និងមន្ត្រីរបស់លន់ ណល់ ជាច្រើននៅទួលពោធិ៍ជ្រៃ និងស្រុក១២ គឺត្រូវបានរៀបចំផែនការ និងត្រូវបានប្រព្រឹត្ត ជាផ្នែកមួយនៃដំណាក់កាលទីមួយនៃការជម្លៀសប្រជាជនដោយបង្ខំ ហើយគួរតែត្រូវបានជំនុំជម្រះជាមួយនឹងការជម្លៀសប្រជាជនដោយបង្ខំក្នុងសវនាការនេះ។ សហព្រះរាជអាជ្ញាសូមលើកឡើងថា សវនាការលើកដំបូងនេះ គួរបានធ្វើការបង្ហាញដោយសមហេតុសមផលត្រឹមកម្រិតអប្បបរមានៃឧក្រិដ្ឋកម្មនានាដែលបានកើតឡើង នៅក្នុងរង្វង់បរិបទទូលំទូលាយជាងនេះនៃការជម្លៀសចេញដោយបង្ខំ រួមទាំងលទ្ធផលរបស់វាផង។

១៩- ការពង្រីកបន្ថែមនូវវិសាលភាពនៃសវនាការលើកដំបូង ដើម្បីរួមបញ្ចូលនូវទីតាំងឧក្រិដ្ឋកម្មនានាក៏នឹងធ្វើឱ្យមានការតភ្ជាប់គ្នា ដោយត្រឹមត្រូវនៃការជម្លៀសចេញដោយបង្ខំទៅនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលបានចោទប្រកាន់ទៅលើជនជាប់ចោទដូចមាននៅក្នុងដីកាដំណោះស្រាយ។ ដីកាដំណោះស្រាយបានកំណត់បទចោទលើការជម្លៀសប្រជាជនចេញដោយបង្ខំពីរដ្ឋធានី និងក្រុងនានាឱ្យទៅកាន់តំបន់ជនបទ ថាជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិដែលបានប្រព្រឹត្តិឡើងតាមរយៈមធ្យោបាយនៃសហឧក្រិដ្ឋកម្មរួមមួយ ដែលជាក់លាក់គឺៈ អំពើមនុស្សឃាត ការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុខាងនយោបាយ និងអំពើអមនុស្សធម៌ដទៃទៀតតាមរយៈ "ការវាយប្រហារប្រឆាំងនឹងសេចក្តីថ្លៃថ្នូររបស់មនុស្ស" និងការជម្លៀសចេញដោយបង្ខំ[36]។ ដីកាដំណោះស្រាយបានកំណត់បទចោទបន្ថែមទៀតអំពីការជម្លៀសប្រជាជនដំណាក់កាលទីមួយ និងទីពីរ ថាជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិស្តីពីការសម្លាប់រង្គាល[37]។

២០- នៅក្នុងសេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា ដែលតភ្ជាប់ការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញទៅនឹងការសម្លាប់នៅស្រុក១២ និងនៅទួលពោធិ៍ជ្រៃ គឺមិនអាចផ្តាច់ពីគ្នាបានទេ ដែលយ៉ាងហោច

---

[36] **D427** *កំណត់សំគាល់ខាងដើម* លេខ៩ ត្រង់កថាខ័ណ្ឌទី 1525(i) ។

[37] **D427** *កំណត់សំគាល់ខាងដើម* លេខ៩ ត្រង់កថាខ័ណ្ឌទី 1381។

ណាល់ ទៅនឹងវាយតម្លៃត្រឹមត្រូវរបស់តុលាការ៖ (១) ធាតុផ្សំខាងសម្ភារៈគួបផ្សំជាមួយនឹងធាតុផ្សំខាងស្មារតីអំពីការសម្លាប់ ឬការបណ្ដាលឱ្យស្លាប់ សម្រាប់ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្នុងបទមនុស្សឃាត និងការសម្លាប់រង្គាល (២) ធាតុផ្សំខាងសម្ភារៈគួបផ្សំជាមួយនឹងធាតុផ្សំខាងស្មារតីអំពីការប្រព្រឹត្តិដែលបង្កើត ឬជាផ្នែកមួយនៃការសម្លាប់ជាទ្រង់ទ្រាយធំ សម្រាប់ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្នុងបទការសម្លាប់រង្គាល (៣) លក្ខណៈនៃការដកហូតសិទ្ធិជាមូលដ្ឋាននានា និងធាតុផ្សំដ៏ជាក់លាក់នៃចេតនា សម្រប់ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្នុងបទការធ្វើទុក្ខបុកម្នេញ និង(៤)បរិបទរួមនិងដែលផ្សាភ្ជាប់ទៅនឹងធាតុផ្សំខាងស្មារតី សម្រាប់រាល់ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិទាំងអស់ដែលបានចោទប្រកាន់នៅក្នុងដីកាដំណោះស្រាយ។

## III. ការពង្រីកវិសាលភាពនៃការជំនុំជម្រះដូចដែលបានស្នើឡើងនឹងគោរពសិទ្ធិក្នុងការរៀបចំការការពារក្ដីប្រកបដោយប្រសិទ្ធភាព និងគោរពលក្ខខណ្ឌតម្រូវឱ្យមានការជូនដំណឹងទាន់ពេលវេលាដល់ភាគីនានា

២១- នៅក្នុងសេចក្ដីសម្រេចណាក៏ដោយដើម្បីពង្រីកវិសាលភាពនៃការជំនុំជម្រះក្ដីលើកទីមួយ អង្គជំនុំជម្រះបានបង្ហាញអំពីសារៈសំខាន់នៃសិទ្ធិដែលត្រូវទទួលបានការការពារខ្លួន "ត្រូវបានផ្ដល់ជូននូវឱកាសក្នុងការរៀបចំការការពារបានប្រកបដោយប្រសិទ្ធភាព"[38] និងលក្ខខណ្ឌតម្រូវថាភាគីនានា "ត្រូវបានជូនដំណឹងក្នុងរយៈពេលសមស្រប"[39]។ លក្ខខណ្ឌតម្រូវឱ្យមានការជូនដំណឹងឱ្យបានគ្រប់គ្រាន់អំពីការចោទប្រកាន់នានា និងអំពីកិច្ចដំណើរការនីតិវិធី ដែលបានកំណត់នៅក្នុងមាត្រា ៣៥ថ្មី នៃច្បាប់ អ.វ.ត.ក ឆ្លុះបញ្ចាំងពីលក្ខខណ្ឌនានាដែលបានតម្រូវនៅក្នុងនីតិវិធីព្រហ្មទណ្ឌអន្តរជាតិ និងច្បាប់សិទ្ធិមនុស្ស[40]។

២២- ការពិនិត្យមើលឡើងវិញនូវវិសាលភាពនៃលក្ខខណ្ឌតម្រូវឱ្យមាន**ការជូនដំណឹងគ្រប់គ្រាន់** និងឱ្យមាន**ពេលវេលាគ្រប់គ្រាន់**នៅក្នុងការអនុវត្តរបស់តុលាការ *មិនអចិន្ត្រៃយ៍* បង្ហាញថា៖ (១) ភាពជាក់លាក់នៃការចោទប្រកាន់នានា, អង្គហេតុសត្យានុម័តនានា និងភ័ស្តុតាងដែលបានកំណត់នៅក្នុងដីកាដំណោះ

---

[38] ឯកសារលេខ **E124** ដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី កំណត់សម្គាល់ ១ ខាងលើ នៅកថាខណ្ឌ ៦។

[39] ឯកសារលេខ **E124** ខាងលើ។

[40] រឿងក្ដី Vladimir Tochilovsky *យុត្តិសាស្ត្ររបស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិ និងតុលាការសិទ្ធិមនុស្សអឺរ៉ុប: នីតិវិធី និងភស្តុតាង* (ឆ្នាំ ២០០៨) នៅទំព័រ ២៨០។

ស្រាយ[41] បង្ហាញឲ្យឃើញថា ហួសពីបទដ្ឋានអន្តរជាតិ និង (២) នៅក្នុងកាលៈទេសៈទាំងនេះ រយៈពេលលើសពី១៣ខែ ចាប់តាំងពីការជូនដំណឹងនៃដីកាដំណោះស្រាយ បង្កើតបានជារយៈពេលគ្រប់គ្រាន់ សម្រាប់មេធាវីការពារក្តីធ្វើការរៀបចំការការពារក្តី។

២៣- នៅពេលធ្វើការវាយតម្លៃអំពី*លក្ខខណ្ឌតម្រូវឲ្យមានការជូនដំណឹងគ្រប់គ្រាន់* បញ្ហាចោទសំខាន់ចំពោះអង្គជំនុំជម្រះសាលាដំបូង គឺថា "តើមេធាវីការពារក្តីបានធ្វើការជូនដំណឹងឲ្យបានសមស្របអំពីរឿងក្តី និងមានឱកាសសមស្របក្នុងការស៊ើបអង្កេត និងតទល់ក្នុងរឿងក្តីដែរ ឬទេ"[42]។ ចំណុចនេះត្រូវបានយល់ឃើញថា ត្រូវបញ្ចូលនូវកាតព្វកិច្ចក្នុងការ "ជជែកការពារនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ *ប៉ុន្តែមិនមែនជាភ័ស្តុតាងដែលត្រូវបានបង្ហាញពីអង្គហេតុទាំងឡាយនោះទេ*"[43]។ ការជូនដំណឹងគ្រប់គ្រាន់ អនុវត្តចំពោះបទល្មើសសំខាន់ៗផង និងចំពោះទម្រង់នៃការទទួលខុសត្រូវផង ហេតុនេះហើយ ប្រសិនបើទ្រឹស្តីនៃសហឧក្រិដ្ឋកម្មរួមត្រូវបានយកធ្វើជាសំអាង នៅពេលនោះ ការជូនដំណឹងត្រូវតែរួមបញ្ចូលនូវគោលបំណងនៃសហកម្មឧក្រិដ្ឋកម្មរួម អត្តសញ្ញាណរបស់អ្នកចូលរួម និងលក្ខណៈនៃការចូលរួមរបស់ជនជាប់ចោទក្នុងសហកម្មឧក្រិដ្ឋកម្មនោះ[44]។

---

[41] ឯកសារលេខ **D427** កំណត់សម្គាល់ខាងដើមលេខ៩។

[42] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Théoneste Bagosora* និងអ្នកផ្សេងទៀត, សំណុំរឿងលេខ ICTR-98-41-T សេចក្តីសម្រេចលើសំណើរបស់ Kabiligi សុំចំណុចនានានៃដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលត្រូវបានកែប្រែ (អង្គជំនុំជម្រះសាលាដំបូងរបស់តុលាការ ICTR) ចុះថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ ២០០៥ នៅកថាខណ្ឌ ៥ (ដោយរៀបរាប់ពីរឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Eliézer Niyitegeka* សាលដីកា (អង្គជំនុំជម្រះសាលាឧទ្ធរណ៍របស់តុលាការ ICTR) ចុះថ្ងៃទី ៩ ខែ កក្កដា ឆ្នាំ ២០០៤ នៅកថាខណ្ឌ ១៩៦: "អង្គជំនុំជម្រះសាលាដំបូងគួរតែពិចារណាតាមធម្មតាអំពីបញ្ហាថាតើរដ្ឋអាជ្ញាបានផ្តល់ការជូនដំណឹង ច្បាស់លាស់ និងទាន់ពេលវេលាកាលពីពេលមុនអំពីការចោទប្រកាន់នេះដែលនាំឲ្យមេធាវីការពារក្តីមានឱកាសសមស្រប ក្នុងការដឹកនាំកិច្ចស៊ើបសួរនានា និងរៀបចំចម្លើយរបស់ខ្លួន")។ សូមមើលផងដែរ រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Augustin Bizimungu* និងអ្នកផ្សេងទៀត, សំណុំរឿងលេខ ICTR-00-56-T សេចក្តីសម្រេចលើញត្តិបន្ទាប់បំផុតរបស់ Ndindiliyimana សុំហាមឃាត់រដ្ឋអាជ្ញាកុំឲ្យផ្តើមភស្តុតាងស្តីពីអង្គហេតុសត្យានុម័តសំខាន់ៗ ដែលមិនត្រូវបានជជែកការពារនៅក្នុងដីកាបញ្ជូនរឿង ទៅជំនុំជម្រះតាមរយៈសាក្សី Anf (អង្គជំនុំជម្រះសាលាដំបូងរបស់តុលាការ ICTR) ចុះថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០០៦ នៅកថាខណ្ឌ ២៧។

[43] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Miroslav Kvočka* និងអ្នកផ្សេងទៀត, សំណុំរឿងលេខ IT-98-30/1-A សាលដីកា (អង្គជំនុំជម្រះសាលាឧទ្ធរណ៍របស់តុលាការ ICTY) ចុះថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០០៥ នៅកថាខណ្ឌ ២៧ ["សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ *Kvočka*" សេចក្តីបញ្ជាក់បន្ថែម]។

[44] សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ *Kvočka ដូចខាងលើ* នៅកថាខណ្ឌ ៦៥។

២៤- នៅក្នុងរឿងក្ដីបច្ចុប្បន្ននេះ ដីកាដំណោះស្រាយបញ្ជាក់លម្អិតអំពីការចោទប្រកាន់ជាក់លាក់នានាលើជនជាប់ចោទម្នាក់ៗ បានពិណនាអំពីទម្រង់នៃការទទួលខុសត្រូវដែលត្រូវបានលើកឡើងយ៉ាងពិស្ដារលើចំណុចខ្លះ ព្រមទាំងផ្ដល់នូវអង្គហេតុដែលពាក់ព័ន្ធទាំងអស់ និងហួសពីបទដ្ឋានអន្តរជាតិ - ឯកសារយោងជាង ៥០០០ អំពីសម្ភារៈជាភ័ស្ដុតាង។ ផ្អែកលើមូលដ្ឋាននេះ សហព្រះរាជអាជ្ញាលើកឡើងថា ជនជាប់ចោទនៅក្នុងសំណុំរឿង ០០២ ត្រូវបានជូនដំណឹងយ៉ាងពេញលេញ និងយ៉ាងត្រឹមត្រូវអំពីការចោទប្រកាន់នានា និងករណីដែលត្រូវឆ្លើយ រួមទាំងករណីពាក់ព័ន្ធទៅនឹងទីតាំងឧក្រិដ្ឋកម្មបន្ថែមចំនួនបីដែលបានលើកឡើងនៅក្នុងសំណើសុំនេះ។

២៥- នៅពេលធ្វើការវាយតម្លៃអំពីលក្ខខណ្ឌតម្រូវឱ្យមានពេលវេលាគ្រប់គ្រាន់ ដើម្បីរៀបចំការការពារ អង្គជំនុំជម្រះសាលាដំបូងរបស់តុលាការ ICTY បានលើកឡើងថា ការវាយតម្លៃមួយករណីម្ដងៗ នឹងកំណត់លក្ខខណ្ឌជាចាំបាច់ថា៖

> *វាមិនអាចទៅរួចទេ ក្នុងការកំណត់បទដ្ឋានស្ដីពីអ្វីដែលបង្កើតជាពេលវេលាគ្រប់គ្រាន់ ក្នុងការរៀបចំការការពារ ពីព្រោះនេះជាអ្វីដែលអាចរងការប៉ះពាល់ពីកត្តាមួយចំនួន រួមទាំងភាពស្មុគ្រស្មាញនៃរឿងក្ដី និងការបង្ខំទាមទារដែលមានលក្ខណៈប្រទាញប្រទង់គ្នាដែលកើតឡើងនៅពេលដំណាលគ្នា ដូចជាការពិចារណាអំពីផលប្រយោជន៍របស់ជនជាប់ចោទផ្សេងៗទៀត ជាដើម*[45]។

២៦- ជាឧទាហរណ៍ នៅក្នុងការជំនុំជម្រះរឿងក្ដី *Delalić* ដែលរងការចោទប្រកាន់ច្រើនបទល្មើស និងមានលក្ខណៈស្មុគ្រស្មាញ អង្គជំនុំជម្រះសាលាដំបូងរបស់តុលាការ ICTY បានពិចារណាអំពីភាពគ្រប់គ្រាន់នៃពេលវេលាសម្រាប់ការរៀបចំនានា រយៈពេលមួយខែ មុនពេលចាប់ផ្ដើមសវនាការ និងយល់ឃើញថា រយៈពេល៨ខែ គិតចាប់ពីការចូលខ្លួនលើកដំបូងគឺ "ជារយៈពេលគ្រប់គ្រាន់ [សម្រាប់មេធាវី] ធ្វើការរៀបចំខ្លួនស្របតាមច្បាប់ផង និងតាមនីតិវិធីផង"[46]។ អង្គជំនុំជម្រះសាលាដំបូងបានធ្វើការថ្លឹងថ្លែងទៅលើអង្គហេតុដែលថា សហជនជាប់ចោទម្នាក់ "បានតវ៉ាយ៉ាងខ្លាំង"[47] ចំពោះការពន្យារពេលថែមទៀតនៅក្នុងការចាប់ផ្ដើមធ្វើការជំនុំជម្រះ។

---

[45] *រឿងក្ដី រដ្ឋអាជ្ញា តទល់នឹង Zejnil Delalić* និងអ្នកផ្សេងទៀត, សំណុំរឿងលេខ IT-96-21-T សេចក្ដីសម្រេចលើសំណើសុំលើកថ្ងៃសវនាការ (អង្គជំនុំជម្រះសាលា ដំបូងរបស់តុលាការ ICTY) ចុះថ្ងៃទី ៣ ខែ កុម្ភៈ ឆ្នាំ ១៩៩៧ នៅកថាខណ្ឌ ១៩។

[46] *ដូចខាងលើ* នៅកថាខណ្ឌ ២៦។

[47] *ដូចខាងលើ* នៅកថាខណ្ឌ ២៦។

២៧- នៅក្នុងអម្លុងពេលនៃកិច្ចស៊ើបសួររហូតទល់ពេលកំណត់សម្រេចលើបណ្តឹងសាទុក្ខដែលកើតចេញមកពីដីកាសន្និដ្ឋានស្ថាពរ (គឺថាថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១០), សហជនជាប់ចោទទាំបីនាក់មានឱកាសដើម្បីតាមដានមើលនូវភ័ស្តុតាងដែលកំពុងត្រូវបានគេដាក់បញ្ចូលនៅក្នុងសំណុំរឿង និងចូលរួមនៅក្នុងការស៊ើបសួរ ថាតើក្នុងនាមជាជនសង្ស័យ ឬជាជនត្រូវចោទ ដូចដែលបានចែងជាពិសេសដោយវិធាន ៥៥(៦) ៥៥(១) ៥៧(២) ៥៨(៦) ៦១(៤) និង៦៦(៣) នៃវិធានផ្ទៃក្នុង។ នៅក្នុងដំណាក់កាលនេះនៃដំណើរការនីតិវិធី មេធាវីការពារក្តីទាំងអស់ និងដើមបណ្តឹងរដ្ឋប្បវេណីបានដាក់សេចក្តីសន្និដ្ឋាន និងបណ្តឹងឧទ្ធរណ៍ចូលទៅក្នុងសំណុំរឿង។ វាច្បាស់ណាស់មិនអាចឲ្យប្រកែកបានទេថា មេធាវីការពារក្តីត្រូវបានគេជូនដំណឹងឲ្យដឹងហើយ ពីភ័ស្តុតាងដែលប្រឆាំងនឹងសហជនជាប់ចោទ ដោយផ្អែកលើមូលដ្ឋានដែលមានការវិវឌ្ឍន៍មួយ ចាប់តាំងពីការឃុំខ្លួនសហជនជាប់ចោទជាបណ្តោះអាសន្នពីដើមដំបូងមក កាលពីក្នុងខែវិច្ឆិកា ឆ្នាំ២០០៧ ដែលមានរយៈពេលជាងបួនឆ្នាំមកហើយ។

២៨- ដីកាដំណោះស្រាយត្រូវបានជូនដំណឹងដល់គ្រប់សហជនជាប់ចោទ ដើមបណ្តឹងរដ្ឋប្បវេណី និង មេធាវីរបស់ពួកគេ នៅថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១០។ សវនាការបានចាប់ផ្តើមនៅថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១១[48]។ សហព្រះរាជអាជ្ញាលើកឡើងថា រយៈពេល១៤ខែ គិតចាប់ពីថ្ងៃជូនដំណឹងអំពីការបញ្ចប់ការចោទប្រកាន់នានារហូតដល់ពេលសវនាការ គឺមានរយៈពេលហួសពីការគ្រប់គ្រាន់ហើយសម្រាប់ធ្វើការរៀបចំឆ្លើយទៅនឹងរឿងក្តីបានពេញលេញហើយ ហេតុដូច្នេះហើយ ការបន្ថែមផ្នែកណាមួយនៃដីកាដំណោះស្រាយ នៅក្នុងអំឡុងពេលសវនាការ នឹងមិនប៉ះពាល់ ឬបំផ្លាញលក្ខខណ្ឌតម្រូវឲ្យមានការជូនដំណឹងគ្រប់គ្រាន់នៅក្នុងករណីនេះទេ។ ការបញ្ជាក់ហេតុផលដូចគ្នា *ការប្រែប្រួលជាចាំបាច់ដែលបានធ្វើឡើង* ចំពោះការជូនដំណឹងដល់ភាគីផ្សេងៗទៀតនៃកិច្ចដំណើរការនីតិវិធី។

## IV. ការពង្រីកវិសាលភាពនៃសវនាការដំណាក់កាលទី១ អាចជម្រុញឲ្យមានប្រសិទ្ធភាពនីតិវិធីទូលំទូលាយ

[48] ឯកសារលេខ **E131** ដីកាកំណត់កាលបរិច្ឆេទនៃការធ្វើសេចក្តីសន្និដ្ឋានចោទប្រកាន់ និងសវនាការលើអង្គសេចក្តីនៃសំណុំរឿង ០០២ ចុះថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០១១។

២៩- សហព្រះរាជអាជ្ញាសូមជូនសេចក្ដីសន្និដ្ឋានថា ការពន្លាតវិសាលភាពនៃសវនាការក្នុងដំណាក់កាលនេះនៃកិច្ចដំណើរការនីតិវិធី នឹងនាំឲ្យមានផលប្រយោជន៍អំពីការដាក់បង្ហាញភ័ស្តុតាងនានា ដែល មានជារចនាសម្ព័ន្ធ និងបញ្ចូលគ្នាបានល្អ, ការធ្វើឲ្យមានប្រសិទ្ធភាពក្នុងការប្រើប្រាស់ពេលវេលាសួរសំនួរចំពោះសាក្សីនានាដែលអាចផ្ដល់ភ័ស្តុតាងជាសក្ខានុពលពាក់ព័ន្ធទៅនឹងការដាក់បង្ហាញនូវកម្រងឧក្រិដ្ឋកម្មធ្ងន់ធ្ងរនានា ក៏ដូចជា គោលនយោបាយដ៏ទូលំទូលាយស្ដីពីសហឧក្រិដ្ឋកម្មរួម ដែល បានលើកឡើងចោទប្រកាន់ ហើយនិង ការកាត់បន្ថយនូវការចាំបាច់ក្នុងការកោះហៅម្ដងទៀតនូវ ភាគីដើមបណ្ដឹងរដ្ឋប្បវេណី និងសាក្សីនានាដែលនៅក្នុងចំណោមនោះ មកទល់ពេលនេះ គេបានស្ដាប់ចម្លើយមួយចំនួនតូចរួចហើយ។

៣០- យ៉ាងហោចណាស់មានដើមបណ្ដឹងរដ្ឋប្បវេណី សាក្សី និងអ្នកជំនាញ ចំនួន២១នាក់ ដែល*បច្ចុប្បន្ននេះមាននៅក្នុងបញ្ជីឈ្មោះមួយផ្នែករបស់អង្គជំនុំជម្រះ* សម្រាប់សំណុំរឿង០០២/១ ក៏អាចនឹងមានលទ្ធភាពផ្ដល់ភ័ស្តុតាង ទាក់ទងនឹងគោលនយោបាយដ៏ទូលំទូលាយស្ដីពីសហឧក្រិដ្ឋកម្មរួម ដែលបានលើកឡើងចោទប្រកាន់ពាក់ព័ន្ធនឹងប្រព្រឹត្តិកម្មលើ "ពួកខ្មាំង" ឬការអនុវត្តនូវគោលនយោបាយទាំងនេះនៅតាមទីតាំងឧក្រិដ្ឋកម្មនានាដែលបានលើកស្នើឡើងបន្ថែមនេះ[49]។ សាក្សី និង អ្នកជំនាញចំនួន១០នាក់ បន្ថែមទៀតពីក្នុង*បញ្ជីឈ្មោះបច្ចុប្បន្នរបស់អង្គជំនុំជម្រះ* នឹងត្រូវផ្ដល់ភ័ស្តុតាងអំពីការបោសសម្អាតនានា និងការដែលពួកគេមានជាប់ទាក់ទងទៅនឹងមន្ទីរសន្តិសុខស-២១[50]។ ការត្រួតគ្នាដ៏សំខាន់នេះ គាំទ្រដល់សេចក្ដីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញាដែលថាការពន្លាតវិសាលភាពសវនាការដែលបានស្នើឡើងនេះ នឹងធ្វើឲ្យកិច្ចដំណើរការនីតិវិធីទាំងមូលមានប្រសិទ្ធភាព។ នៅក្នុងករណីជាច្រើន ការសួរសំនួរពាក់ព័ន្ធទៅនឹងការស្នើឲ្យពន្លាតវិសាលភាពនេះ នឹងមានចរិតលក្ខណៈត្រូវទៅតាមការសួរសំនួរនៅក្នុងវិសាលភាពសវនាការបច្ចុប្បន្ននេះ ទាំងសមហេតុផល និងទាំងមានប្រសិទ្ធភាព។

---

[49] សាក្សី TCW-604, TCCP-142, TCW-542, TCW-797 និង TCW-601 (ពាក់ព័ន្ធនឹងរចនាសម្ព័ន្ធគ្រប់គ្រង បកក/កម្ពុជាប្រជាធិបតេយ្យ)។ សាក្សី TCW-320, TCW-609, TCW-475, TCW-694, TCW-586, TCW-724, TCW-323, TCW-796, TCW-490, TCW-707, TCW-794, TCW-234, TCW-583 និង TCW-321 (ពាក់ព័ន្ធនឹងរចនាសម្ព័ន្ធគ្រប់គ្រង និងដំណើរការប្រព្រឹត្តទៅនៃក្រសួងនានារបស់កម្ពុជាប្រជាធិបតេយ្យ)។ សាក្សី TCW91 និង TCCP-186 (ពាក់ព័ន្ធនឹងវគ្គរៀនសូត្រនយោបាយ)។

[50] សាក្សី TCW-428, TCW-645, TCW-487, TCW-297, TCW-110 និង TCW-326 (ពាក់ព័ន្ធនឹងការបោសសម្អាតកម្មាភិបាល)។ សាក្សី TCW-281 (ពាក់ព័ន្ធទៅនឹងស-២១)។ ក៏ដូចជាអ្នកជំនាញ TCE-11, TCE-41 និង TCE-44 (ពាក់ព័ន្ធទៅនឹងប្រព័ន្ធមន្ទីរសន្តិសុខនៃកម្ពុជាប្រជាធិបតេយ្យ ដែលមានមន្ទីរស-២១ ជាផ្នែកមួយផងដែរ)។

៣១- តាមវិធីពន្យល់ដោយមានឧទាហរណ៍បញ្ជាក់នៅក្នុងកំណត់ហេតុនៃការស្តាប់ចម្លើយរបស់គាត់[51] ដើមបណ្តឹងរដ្ឋប្បវេណី TCCP-185 បានបញ្ជាក់ថា កាលពីថ្ងៃទី២០ ខែកញ្ញា ឆ្នាំ១៩៧៨ ដោយបាននិយាយខ្លាំងៗអំពី "ការចាត់ចែងគ្រប់គ្រងមិនត្រឹមត្រូវរបស់អង្គការ"[52] គាត់ត្រូវបានគេហៅឲ្យធ្វើដំណើរមកភ្នំពេញជាមួយគ្នាមួយក្រុមដែលមានឈ្មោះកម្មាភិបាល៧នាក់ទៀតយ៉ាងតិច ដែលត្រូវបានគេកំណត់អត្តសញ្ញាណថាជា "អ្នកតស៊ូជាយូរមកហើយ"[53]។ នៅក្នុងកំណត់ហេតុមិនមានបញ្ជាក់អំពីការរំឭឡើងវិញនូវការចងចាំរបស់ដើមបណ្តឹងរដ្ឋប្បវេណីអំពីជោគវាសនានៃពួកកម្មាភិបាលនានាដែលជាសហការីរបស់ខ្លួនឡើយ។ នៅក្នុងពេលដែលត្រូវបានចោទសួរសំនួរដោយសហមេធាវីការពារក្តីរបស់ នួន ជា ក្នុងអង្គុំពេលនៃដំណើរការសវនាការជំនុំជម្រះក្តីបច្ចុប្បន្ននេះ គាត់បានផ្តល់សក្ខីកម្មលើអង្គហេតុដដែលដូចគ្នាភាគច្រើនបំផុតដែលនិយាយថា គាត់បានវិលត្រឡប់មកភ្នំពេញនៅក្នុងឆ្នាំ១៩៧៨[54] ប៉ុន្តែលើសពីនេះ គាត់បានបញ្ជាក់ឈ្មោះកម្មាភិបាលបួននាក់ ក្នុងចំណោមកម្មាភិបាលទាំងឡាយដែលបានធ្វើដំណើរជាមួយគាត់ដែលត្រូវបានគេដាក់ទៅលើឡានកាមីញ៉ុងហើយ "យកចេញទៅ"[55]។ គាត់បានបន្ថែមថា គាត់មិនដឹងថាតើកម្មាភិបាលទាំងបួននាក់នោះ "ត្រូវបានគេយកទៅទួលស្លែង" ឬទៅណានោះទេ?[56]។ ការពិនិត្យមើលឡើងវិញមួយទៅលើប្រតិចារិកនៃសវនាការឃើញយ៉ាងច្បាស់ថាបានគាំទ្រចំពោះទស្សនៈដែលយល់ឃើញថា គ្រាន់តែប៉ុន្មាននាទីនៃការសួរសំនួរបន្ថែមប៉ុណ្ណោះ អង្គជំនុំជម្រះ ឬភាគីនានានឹងអាចបំពេញបានចប់សព្វគ្រប់នូវភស្តុតាងនេះរបស់ដើមបណ្តឹងរដ្ឋប្បណីយលើរាល់បញ្ហាទាំងអស់ ដែលទាក់ទងទៅនឹងសំណើសុំពង្រីកវិសាលភាពសវនាការជំនុំជម្រះក្តី។ តក្កភាពស្រដៀងគ្នានេះត្រូវបានយកមកអនុវត្តចំពោះសក្ខីកម្មសាក្សីនៃដើមបណ្តឹងរដ្ឋប្បវេណី សាក្សី និងអ្នកជំនាញដទៃទៀតភាគច្រើនដែលបានបញ្ជាក់អត្តសញ្ញាណខាងលើ។

៣២- តាមពិតទៅ ការពង្រីកវិសាលភាពនៃសវនាការជំនុំជម្រះក្តីដូចដែលបានស្នើសុំ គឺវាតម្រូវឲ្យកោះហៅដើមបណ្តឹងរដ្ឋប្បវេណី សាក្សី និងអ្នកជំនាញបន្ថែមក្នុងចំនួនមួយដែលមានកំរិត។ បញ្ជីដើមដំបូង

---

[51] កំណត់ហេតុនៃការស្តាប់ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី TCCP-185 ត្រូវបានអង្គជំនុំជម្រះទទួលយកទាងស្រុង: សូមអានឯកសារលេខ **E3/125**, កំណត់ហេតុនៃការស្តាប់ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី [TCCP-185], ចុះថ្ងៃទី៨ ខែវិច្ឆិកា ២០០៩។

[52] ឯកសារលេខ **E3/125**, *នៅកន្លែងដូចគ្នាដដែល* ត្រង់ ក១១, ទំព័រ ៦។

[53] ឯកសារលេខ **E3/125**, *នៅកន្លែងដូចគ្នា ដដែល* ត្រង់ ក១១, ទំព័រ ៧។

[54] ឯកសារលេខ **E1/25.1** ប្រតិចារឹក, ចុះថ្ងៃទី១១មករា២០១២ ត្រង់ទំព័រ ៦០: ១៤: ២២។

[55] ឯកសារលេខ **E1/25.1** *នៅកន្លែងដូចគ្នាដដែល* ត្រង់ទំព័រ ៦១: ១៦:១៧។

[56] ឯកសារលេខ **E1/25.1** *នៅកន្លែងដូចគ្នាដដែល* ។

របស់សហព្រះរាជអាជ្ញាអនុលោមតាមវិធាន៨០នៃវិធានផ្ទៃក្នុង បានផ្តល់អត្តសញ្ញាណនៃសាក្សីចំនួនប្រាំនាក់ដែលទាក់ទងនឹងទួលពោធិ៍ជ្រៃ។ សាក្សីចំនួន១២នាក់ ដែលទាក់ទងនឹងកន្លែងសម្លាប់មនុស្សស្រុក១២។ និងដើមបណ្តឹងរដ្ឋប្បវេណីម្នាក់ និងសាក្សីប្រាំនាក់ដែលទាក់ទងនឹងមន្ទីរស-២១[57]។ នៅក្នុងពេលដែលយល់ព្រមទាំងស្រុងទៅលើសមត្ថកិច្ចរបស់អង្គជំនុំជម្រះ ដើម្បីឲ្យធ្វើជាអ្នកកំណត់សំរេចថាតើសាក្សីណាខ្លះដែលអាចជួយនៅក្នុងការបង្ហាញការពិតបានប្រសើរជាងគេបំផុតដែលទាក់ទងទៅនឹងទីកន្លែងឧក្រិដ្ឋកម្មបន្ថែមដែលបានស្នើសុំ។ សហព្រះរាជអាជ្ញាសូមលើកឡើងថាពេលវេលាបន្ថែមដែលតម្រូវសំរាប់ការស្តាប់ចម្លើយសាក្សី ត្រូវបានធ្វើយុត្តិកម្មយ៉ាងពេញលេញដោយគិតគូរពិចារណាចំពោះផលប្រយោជន៍នៃយុត្តិធម៌ជាធំលើសអ្វីៗទាំងអស់ ដូចដែលបានលើកឡើងខាងលើ។

## V. ដំណោះស្រាយដែលបានស្វែងរក

៣៣- ហេតុដូច្នេះ សហព្រះរាជអាជ្ញាស្នើសុំឲ្យអង្គជំនុំជម្រះសាលាដំបូងសម្រេចថា ការពង្រីកវិសាលភាពនៃការជំនុំជម្រះនៅក្នុងសំណុំរឿង០០២/១ នឹងជាប្រយោជន៍ភាពយុត្តិធម៌ និងបង្គាប់ឲ្យដាក់ទីតាំងឧក្រិដ្ឋកម្មនានាដូចខាងក្រោម និងអង្គហេតុចោទប្រកាន់នានាពីដីកាដំណោះស្រាយ គួរត្រូវយកមកដាក់នៅក្នុងវិសាលភាពនៃសំណុំរឿង០០២/១នេះ៖

(ក) ការសម្លាប់អ្នកជម្លៀស ១៧ មេសា ១៩៧៥ នៅទីតាំងក្នុងកំពង់ត្រឡាចលើ (ស្រុក១២) ខេត្តកំពង់ឆ្នាំង (តំបន់៣១ នៃភូមិភាគបស្ចិម) (កថាខ័ណ្ឌទី៦៩១, ៦៩៣-៦៩៧ នៃដីកាដំណោះស្រាយ)។

(ខ) ការសម្លាប់អតីតយោធា និងមន្ត្រីរបស់ លន់ ណល់ ក្នុងឆ្នាំ១៩៧៥ ទីតាំងសម្លាប់នៅទួលពោធិ៍ជ្រៃ ស្រុកកណ្តៀង ខេត្តពោធិ៍សាត់ (តំបន់៧ នៃភូមិភាគពាយ័ព្យ) (កថាខ័ណ្ឌទី៦៩៨-៧១១ នៃដីកាដំណោះស្រាយ និង

[57] ឯកសារលេខ **E9/4.1** ឧបសម្ព័ន្ធសម្ងាត់: ដីកាបង្គាប់ឲ្យសាក្សីចូលបង្ហាញខ្លួននៅក្នុងសវនាការ ដែលបានស្នើសុំ, ចុះថ្ងៃទី១៧ មករា ២០១១។

(គ) មន្ទីរសន្តិសុខ ស-២១ និងទីតាំងសម្លាប់មនុស្សដែលពាក់ព័ន្ធនៅជើងឯក ខេត្តកណ្តាល (កថាខ័ណ្ឌទី៤១៥-៤៧៥ នៃដីកាដំណោះស្រាយ) *រួមទាំង* ការបោសសម្អាតកម្មាភិបាលមកពីភូមិភាគឧត្តរថ្មី ភូមិភាគកណ្តាល(ឧត្តរចាស់) និងភូមិភាគបូព៌ា ដែលបានបញ្ជូនទៅមន្ទីរស-២១ (កថាខ័ណ្ឌទី១៩២-២០៤ នៃដីកាដំណោះស្រាយ) ប៉ុន្តែ *មិនរាប់បញ្ចូល* ការដ្ឋានព្រៃស ក្នុងស្រុកដង្កោរ ខេត្តកណ្តាលទេ។

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី២៧ ខែមករាឆ្នាំ២០១២ | **លោកស្រី ជា លាង**<br>សហព្រះរាជអាជ្ញា | ភ្នំពេញ | [signature] |
| | **លោក** Andrew CAYLEY<br>សហព្រះរាជអាជ្ញា | | [signature] |